

# យុត្តិធម៌ផ្នែកច្បាប់ – យុទ្ធសាស្ត្រផ្ដោតអាយស៊ីស៊ី

*“គ្មានកុមារណាម្នាក់ត្រូវប្រឈមមុខនឹងអំពើហិង្សា ការរំលោភបំពាន និងការប្រងើយកន្តើយឡើយ។ ប៉ុន្តែនៅកម្ពុជាវិញ កុមារនៅតែបន្តស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់។” យោងតាមទិន្នន័យឆ្នាំ២០១៩របស់អង្គការ យូនីសេហ្វ បានឱ្យដឹងថាកុមារម្នាក់ក្នុងចំនោមកុមារពីរនាក់ត្រូវបានទទួលរង នូវអំពើហឹង្សាលើរាងកាយក្នុងលក្ខណៈធ្ងន់ធ្ងរ ហើយកុមារម្នាក់ក្នុង ចំណោមបួននាក់ត្រូវបានទទួលរងនូវការរំលោភបំពានផ្លូវចិត្ត ហើយម្នាក់ក្នុងចំណោម២០នាក់(ក្មេងស្រីនិងប្រុស) ត្រូវបានទទួលរងការរំលោភ បំពានផ្លូវភេទ។ កុមារជាច្រើន ត្រូវបានជួញដូរកម្លាំងពលកម្ម ហើយកុមារជាច្រើនផ្សេងទៀតត្រូវបានទទួលរងការបំបែកចេញពីគ្រួសារ នឹងត្រូវបានគេយកទៅដាក់នៅមណ្ឌលថែទាំដោយខុសពីស្ថានភាពពិតប្រាកដរបស់កុមារ[1]។*

រាជរដ្ឋាភិបាលកម្ពុជាកំពុងតែចាត់វិធានការយ៉ាងតឹងរឹង និងបានដាក់ចេញច្បាប់ជាច្រើនដើម្បីការពារកុមារ។ ច្បាប់ទាំងអស់នោះគឺមានដូចជា ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ(២00៨) ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ(២00៥) និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន(២០១៦)។ រដ្ឋាភិបាលក៏បានផ្ទេរការងារការពារកុមារទៅកាន់ថ្នាក់ក្រោមជាតិផងដែរដូចជាទៅកាន់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ(គ.ក.ស.ក) នៅថ្នាក់ខេត្តនិងស្រុក និងគណៈកម្មាធិការកិច្ចការនារី និងកុមារ(គ.ក.ន.ក) នៅកម្រិតថ្នាក់ប្រតិបត្តិការ។

នៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលតួនាទីនិងទំនួលខុសត្រូវរបស់ គ.ក.ស.ក និង គ.ក.ន.ក ត្រូវបានបញ្ជាក់យ៉ាងច្បាស់។ សម្រាប់ គ.ក.ស.ក ពួកគាត់មានតួនាទីជាអ្នកផ្តល់សេវាប្រឹក្សាយោបល់ ណែនាំ គាំទ្រ និងសម្របសម្រួលទៅកាន់ស្ត្រីនិងកុមារ។ សម្រាប់ គ.ក.ន.ក ពួកគាត់មានតួនាទីនិងទំនួលខុសត្រូវដូចជា រៀបចំផែនការការងារនិងថវិកាប្រចាំឆ្នាំ ណែនាំនិងជួយដល់ក្រុមប្រឹក្សាឃុំ លើកកម្ពស់ការយល់ដឹងអំពីច្បាប់និងគោលនយោបាយផ្សេងទៀតដែលទាក់ទងនឹងសិទ្ធិរបស់ស្ត្រីនិងកុមារ។

កាលពីដើមឆ្នាំនេះ គម្រោងសិទ្ធិកុមាររបស់អាយស៊ីស៊ី បានចាប់ផ្តើមធ្វើការស្ទង់មតិជាមូលដ្ឋាននៅខេត្តស្វាយរៀងនិងតាកែវ ដើម្បីធ្វើការស្វែងយល់ អំពីដំណើរការរបស់ គ.ក.ស.ក និង គ.ក.ន.ក។ តាមរយៈការស្ទង់មតិនេះ បានបង្ហាញឱ្យឃើញថាប្រហែលជា២៩% (ឬ១៨លើ៦៣នៃចំនួនអ្នកចូលរួម)នៃ គ.ក.ន.ក នៅក្នុងខេត្តទាំងពីរមិនសូវបានយល់ច្បាស់អំពីតួនាទី និងទំនួលខុសត្រូវរបស់ពួកគាត់ឡើយ។ លើសពីនេះទៀត ៧0%នៃ គ.ក.ន.ក ជឿជាក់ថាពួកគាត់មានទំនុកចិត្តត្រឹមកម្រិតមធ្យមទេក្នុងការបំពេញភារកិច្ចរបស់ពួកគាត់ ប្រសិនបើប្រៀបធៀបទៅនឹង៣0% ដែលមានទំនុកចិត្តខ្ពស់ក្នុងការបំពេញភារកិច្ច។ គម្រោងសិទ្ធិកុមារ នឹងធ្វើការប្រើប្រាស់ទិន្នន័យនេះដោយមានចេតនា និងគោលដៅច្បាស់លាស់ក្នុងការបង្វឹក និងកសាងសមត្ថភាពសមាជិក គ.ក.ស.ក និង គ.ក.ន.ក ដើម្បីឱ្យពួកគាត់បំពេញតួនាទីនិងទំនួលខុសរបស់ពួកគាត់បានកាន់តែល្អ ក្នុងការការពារកុមារ ការអនុវត្តច្បាប់ និងសិទ្ធិកុមារ។

បន្ទាប់ពីការស្ទង់មតិត្រូវបានបញ្ចប់ គម្រោងសិទ្ធិកុមារ បានរៀបចំសិក្ខាសាលាស្តីអំពីចក្ខុវិស័យ របស់គម្រោងទៅដល់ គ.ក.ស.ក និង គ.ក.ន.ក មេភូមិ និងដៃគូអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត នៅក្នុងខេត្តទាំងពីរ ដូចបានឃើញនៅក្នុងរូបភាពខាងលើ។ សិក្ខាសាលា ស្តីអំពីចក្ខុវិស័យរបស់គម្រោង ត្រូវបានធ្វើឡើងក្នុងគោលបំណងបង្ហាញពីគោលបំណងនិងគោលដៅរបស់គម្រោងសិទ្ធិកុមារ និងដើម្បីបង្ហាញពីសារៈ សំខាន់នៃកិច្ចសហការដោយផ្ទាល់រវាងគម្រោងនិងអ្នកពាក់ព័ន្ធក្នុងតំបន់ ក្នុងការការពារកុមារ និងការបំពេញសិទ្ធិកុមារ។ អ្នកចូលរួមម្នាក់ បាននិយាយថា “គម្រោងសិទ្ធិកុមាររបស់អាយស៊ីស៊ី មានកម្មវិធីល្អៗណាស់ ដូច្នេះទោះបីពួកយើងរវល់យ៉ាងណាក៏ដោយ ក៏យើងនឹងផ្តល់អាទិភាពក្នុងការសហការជាមួយគម្រោងសិទ្ធិកុមារដែរ ពីព្រោះគម្រោងនេះព្យាយាម ធ្វើឱ្យប្រសើរឡើងដល់សហគមន៍របស់យើង” ។

ក្រុមការងាររបស់គម្រោងសិទ្ធិកុមារ បានផ្តល់ការបណ្តុះបណ្តាលមួយចំនួនទៅដល់សមាជិក គ.ក.ស.ក និង គ.ក.ន.ក ស្តីពីយុត្តិធម៌ផ្នែកច្បាប់និងការការពារកុមារ។ គម្រោងនេះក៏ខិតខំស្វែងរកការសហការគ្នាកាន់តែខ្លាំងរវាងរដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងតំបន់ ដើម្បីខិតខំឱ្យមានការចូលរួមគ្នាកាន់តែខ្លាំងក្នុងការការពារកុមារកម្ពុជា។

អាយស៊ីស៊ី ប្រកាន់ជំហរមិនលើកលែងចំពោះគ្រប់ទម្រង់ណាមួយនៃការរំលោភបំពាន ការព្រងើយកន្តើយ និងការកេងប្រវ័ញ្ចលើកុមារ ដែលមានអាយុក្រោម១៨ឆ្នាំ ដោយមិនគិតពីពូជសាសន៍ សង្គមវប្បធម៌ អាយុ ភេទ ពណ៌សម្បុរ ពិការភាព សាសនាឬជំនឿឡើយ។ ដូច្នេះវាពិតជាសំខាន់ខ្លាំងណាស់សម្រាប់ អាយស៊ីស៊ី ក្នុងការសកម្មទៅលើការប្រយុទ្ធប្រឆាំងការរំលោភបំពាន ការធ្វេសប្រហែស និងការកេងប្រវ័ញ្ចមកលើកុមារនៅកម្ពុជា ហើយវាពិតជាសំខាន់ផងដែរសម្រាប់អាយស៊ីស៊ីក្នុងការលើកកម្ពស់ការអនុវត្ត អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ គម្រោងសិទ្ធិកុមាររបស់អាយស៊ីស៊ី ព្យាយាមឆ្ពោះទៅមុខក្នុងការសហការដោយផ្ទាល់ជាមួយនឹង គ.ក.ស.ក គ.ក.ន.ក និងអង្គការសង្គមស៊ីវិលដទៃទៀត ហើយរហូតមកដល់ពេលនេះ ក្រុមការងាររបស់គម្រោង ទទួលបានការលើកទឹកចិត្តយ៉ាងខ្លាំងដោយសារតែមានការចូលរួមដ៏សកម្មពីក្រុមគោលដៅទាំងអស់ក្នុងការធ្វើការ ដើម្បីសុវត្ថិភាពកុមារនៅកម្ពុជា។

កាលបរិច្ឆេទ៖ តុលា ២០១៩

[1] https://www.unicef.org/cambodia/reports/child-protection